# អាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានតែងតាំងឡើងដោយព្រះ ។

## អាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់

សូមសិក្សា ៖

សូមអាន ម៉ាកុស ១០:៦–៩; កូរិនថូស ទី១ ១១:១១ និងសេចក្ដីថ្លែងការណ៍ខាងក្រោមដោយស៊ីស្ទើរ បូនី អិល អូស្ការសុន អតីតប្រធានយុវនារីទូទៅ ។ សូមរកមើលការបង្រៀនអំពីអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ ។



យើងត្រូវបានបង្រៀននៅក្នុងបទគម្ពីរថា « ប៉ុន្តែក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹងអាស្រ័យដល់បុរសដែរ » [ កូរិនថូស ទី១ ១១:១១ ] ។ សម្រាប់អ្នកដែលទទួលភាពពេញលេញនៃពរជ័យបព្វជិតភាព គឺច្បាស់ជាស្វាមី និងភរិយា ដែលបានផ្សារភ្ជាប់នៅក្នុងដំណាក់នៃព្រះអម្ចាស់ ធ្វើការរួមគ្នាក្នុងសេចក្ដីសុចរិត ហើយបន្តនៅស្មោះត្រង់ចំពោះសេចក្ដីសញ្ញារបស់ពួកគេ ។ នេះគឺជាផែនការរបស់ព្រះអម្ចាស់សម្រាប់បុត្រាបុត្រីរបស់ទ្រង់ ហើយគ្មានការពិភាក្សាជាសាធារណៈណា ឬការរិះគន់ណា នឹងផ្លាស់ប្ដូរនូវអ្វីដែលព្រះអម្ចាស់បានប្រកាសនោះដែរ ។. . . ចូរយើងធ្វើជាអ្នកការពារអាពាហ៍ពិពាហ៍ ដូចដែលព្រះអម្ចាស់បានតែងតាំងវាឡើង ដោយបន្តបង្ហាញសេចក្ដីស្រឡាញ់ និងមេត្តាករុណាដល់អ្នកទាំងឡាយដែលមានទស្សនៈខុសពីយើង ។ ( បូនី អិល អូស្ការសុន « Defenders of the Family Proclamation » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៥ )

សូមពិភាក្សា ៖

- តើអាពាហ៍ពិពាហ៍រវាងស្ត្រីម្នាក់ និងបុរសម្នាក់ជួយបំពេញ « ផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់ជោគវាសនាដ៏នៅអស់កល្បជានិច្ចសម្រាប់បុត្រាបុត្រីរបស់ទ្រង់ » យ៉ាងដូចម្ដេច ? ( « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » នៅលើគេហទំព័រ ChurchofJesusChrist.org ) ។

- តើយើងអាចបង្ហាញសេចក្ដីមេត្តាករុណាចំពោះអ្នកទាំងឡាយណាដែលមានទស្សនៈខុសគ្នាដោយរបៀបណា ខណៈដែលនៅតែការពារគោលលទ្ធិរបស់ព្រះអង្គសង្គ្រោះអំពីអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីនោះ ?

## « ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ »

សូមសិក្សា ៖

សូមអាន លោកុប្បត្តិ ១:២៧–២៨; ទំនុកដំកើង ១២៧:៣; ម៉ាកុស ១០:១៣–១៤ និងសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមរកមើលការបង្រៀនរបស់ព្រះអម្ចាស់អំពីកូនចៅ ។



នៅពេលយើងក្រឡេកមើលទៅក្នុងក្រសែភ្នែករបស់ក្មេងម្នាក់ យើងឃើញបុត្រា ឬបុត្រីរបស់ព្រះ ដែលឈរជាមួយយើងក្នុងជីវិតមុនឆាកជីវិតនេះ ។

វាជាឯកសិទ្ធិដ៏វិសេសវិសាលមួយរបស់ស្វាមី និងភរិយាដែលអាចមានកូនបាន ដើម្បីផ្ដល់នូវរូបកាយនៃជីវិតរមែងស្លាប់ដល់បុត្រាបុត្រីខាងវិញ្ញាណរបស់ព្រះទាំងនេះ ។ យើងជឿលើក្រុមគ្រួសារទាំងឡាយ ហើយយើងជឿជាក់លើកូនចៅទាំងអស់ ។

នៅពេលទារកម្នាក់ចាប់កំណើតជាមួយស្វាមី និងភរិយាមួយគូ នោះពួកគេកំពុងតែបំពេញផ្នែកមួយនៃផែនការរបស់ព្រះវរបិតាសួគ៌របស់យើង ដើម្បីនាំកូនៗមកកាន់ផែនដីហើយ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា « នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង—គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » [ ម៉ូសេ ១:៣៩ ] ។ មុនពេលមានអមតភាព នោះវាត្រូវតែមានជីវិតរមែងស្លាប់សិន ។ ( នែល អិល អាន់ឌើរសិន « Children » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៨ )

សូមពិភាក្សា ៖

- តើការមើលទៅកូនៗ និងក្រុមគ្រួសារដោយទស្សនដ៏អស់កល្បមួយ អាចជួយគូស្វាមីភរិយាឲ្យដាក់អាទិភាពដល់ការសម្រេចចិត្តមួយចំនួនរបស់ពួកគេដោយរបៀបណា ?

- តើយើងអាចរៀនអ្វីខ្លះមកពីគំរូរបស់ព្រះអង្គសង្គ្រោះអំពីរបៀបដែលយើងប្រព្រឹត្ត និងប្រាស្រ័យទាក់ទងជាមួយនឹងកូនៗ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៤ by Intellectual Reserve, Inc. All rights reserved. PD80007812_258_201-1